អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
ជាន់ទី ១២ អគារ Exchange Square
ផ្លូវលេខ ១០៦ កែងផ្លូវ ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
AIA.COM

Smart Axiata Co., Ltd.
អគារលេខ ៤៦៤A
មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
SMART.COM.KH

# សេចក្តីប្រកាសព័ត៌មានរួម

## អេ អាយ អេ ខេមបូឌា និង Smart Axiata រួមគ្នាប្រកាសការចាប់ដៃគូ៖ ភាពច្នៃប្រឌិតគាំទ្រដោយបច្ចេកវិទ្យាទំនើបសម្រាប់ការធានារ៉ាប់រងជីវិត

**រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧៖** ក្រុមហ៊ុន អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") និងក្រុមហ៊ុន ស្មាតអាស្យាតា ខូអិលធីឌី ("Smart") បានរួមគ្នាប្រកាសការចាប់ដៃគូរយៈពេលវែង ដែលក្នុងនោះ អេ អាយ អេ ខេមបូឌា នឹងប្រើប្រាស់សេវាកម្មដ៏ទំនើបរបស់ Smart ដើម្បីនាំយកនូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតបែបថ្មី មកជូនប្រជាពលរដ្ឋកម្ពុជា ដើម្បីបំពេញតម្រូវការលើការការពារផ្នែកហិរញ្ញវត្ថុ និងការសន្សំរយៈពេលវែង ដែលកំពុងតែកើនឡើង។

អេ អាយ អេ ខេមបូឌា គឺជាផ្នែកមួយនៃ AIA Group Limited ដែលជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងជីវិតឯករាជ្យចុះបញ្ជីសាធារណៈធំជាងគេបំផុតក្នុងតំបន់អាស៊ី និងជាក្រុមហ៊ុនធានារ៉ាប់រងជីវិតធំជាងគេទីពីរទូទាំងពិភពលោក។ អេ អាយ អេ ខេមបូឌា បានទទួលអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាលពីដើមឆ្នាំនេះ ហើយរំពឹងថានឹងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងពេលឆាប់ៗនេះ។ Smart គឺជាក្រុមហ៊ុនទូរគមនាគមន៍ចល័តឈានមុខគេមួយនៅកម្ពុជា ដែលកំពុងបម្រើប្រជាពលរដ្ឋច្រើនជាង ៨លាននាក់ទូទាំង ២៥ ខេត្ត-ក្រុង ជាមួយនិងសេវាអ៊ិនធឺណិតចល័តល្បឿនលឿនបំផុតនៅកម្ពុជា គឺប្រព័ន្ធ 4G LTE ពីក្រុមហ៊ុន Smart។

Smart នឹងផ្តល់ការគាំទ្រដល់ អេ អាយ អេ ខេមបូឌា ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋកម្ពុជា និងធ្វើឲ្យការផ្តល់ជូនដំណោះស្រាយធានារ៉ាប់រងជីវិតដែលមានបច្ចេកវិទ្យាខ្ពស់បំផុតរបស់ អេ អាយ អេ ខេមបូឌា ដំណើរការទៅបានតាមរយៈបណ្តាញទូរគមនាគមន៍ដែលឈានមុខក្នុងទីផ្សារ និងសេវាកម្មហិរញ្ញវត្ថុចល័តរបស់ខ្លួន។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនទាំងពីរ នឹងសហការគ្នាដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ជីវិតរស់នៅរបស់អ្នកទាំងអស់គ្នា និងចូលរួមលើកកំពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង។

លោក Richard Bates អគ្គនាយកក្រុមហ៊ុន អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា៖ "យើងរីករាយចំពោះការចាប់ដៃគូរយៈពេលវែងជាមួយ Smart។ ដោយមានការគាំទ្រពី Smart អេ អាយ អេ ខេមបូឌា នឹងអាចភ្ជាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋរាប់លាននាក់ និងអាចផ្តល់ជូននូវភាពស្ងប់ចិត្តទៅកាន់ពួកគាត់ តាមរយៈដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតបែបថ្មី។"

លោក Thomas Hundt នាយកប្រតិបត្តិរបស់ក្រុមហ៊ុន Smart ទទួលស្គាល់អំពីសារៈសំខាន់នៃការធានារ៉ាប់រងជីវិត និងបានមានប្រសាសន៍ដោយក្តីសោមនស្សរីករាយដូចគ្នាដែរ ថា៖ "ក្រុមហ៊ុន Smart ជឿជាក់យ៉ាងមុតមាំលើការធ្វើឲ្យជីវិតកាន់តែប្រសើរឡើងទូទាំងប្រទេសកម្ពុជា តាមរយៈការផ្តល់ជូនការភ្ជាប់ទំនាក់ទំនងដ៏ទូលំទូលាយ និងមានល្បឿនលឿនបំផុត ព្រមទាំងសេវាកម្មនានាដែលបន្ថែមអត្ថប្រយោជន៍ដ៏មានគុណភាពដល់អ្នកទាំងអស់គ្នា។ ការចាប់ដៃគូដ៏រំភើបជាមួយនឹង អេ អាយ អេ ខេមបូឌា គឺជាកញ្ចក់មួយឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តឥតស្រាកស្រាន្តរបស់ Smart ឆ្ពោះទៅកាន់គោលដៅមួយនេះ និងអំពីដំណើរឆ្ពោះទៅមុខរបស់យើងក្នុងការ

ក្លាយទៅជានិមិត្តរូបនៃការរស់នៅបែបឌីជីថល។ ជាមួយនឹងសេវាអ៊ិនធឺណិត និងបណ្ដាញ 4G ទូទាំងប្រទេស ដែលបានឈ្នះពានរង្វាន់នោះ យើងជួយលើកកំពស់ការទទួលបានការធានារ៉ាប់រងជីវិត និងត្រួសត្រាយផ្លូវទៅកាន់សុវត្ថិភាពហិរញ្ញវត្ថុសម្រាប់ក្រុមគ្រួសារកម្ពុជាដោយមានប្រសិទ្ធិភាព។”

សេវាធានារ៉ាប់រងជីវិត គឺជាសេវាកម្មថ្មីសម្រាប់ប្រទេសកម្ពុជា។ ដោយឡែកប្រជាពលរដ្ឋដែលចូលចិត្តប្រើប្រាស់បច្ចេកវិទ្យាកំពុងតែកើនឡើង និងកាន់តែយល់ដឹងអំពីគុណសម្បត្តិនៃសេវាកម្មនេះ។ ដូច្នេះ Smart និង អេ អាយ អេ ខេមបូឌា មានទំនុកចិត្តថាការចាប់ដៃគូថ្មីនេះ នឹងនាំទៅរកគុណភាពជីវិតកាន់តែប្រសើរឡើង និងឱកាសកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា។

**អំពី អេ អាយ អេ ខេមបូឌា**

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") គឺជាបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុងរបស់ AIA Group Limited ("AIA" or the "Group") ដែលជាក្រុមហ៊ុនធានារ៉ាប់រងជីវិត ចុះបញ្ជីជាសាធារណៈឯករាជ្យធំបំផុតប្រចាំតំបន់អាស៊ី និងជាក្រុមហ៊ុនធានារ៉ាប់រងជីវិតធំជាងគេទីពីរនៅលើពិភពលោក ដោយយោងតាមទីផ្សារមូលធននីយកម្ម។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន ១៨ នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី ចិន កូរ៉េ ហ្វីលីពីន អូស្រ្តាលី ឥណ្ឌូនេស៊ី តៃវ៉ាន់ វៀតណាម ណូវែលហ្សេឡង់ ម៉ាកាវ ប្រ៊ុយណេ កម្ពុជា ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ ៩៧ ភាគរយនៅសិរីលង្កា ក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម ៤៩ ភាគរយនៅឥណ្ឌូនេស៊ី និងការិយាល័យតំណាងនៅមីយ៉ាន់ម៉ា។ AIA គឺជាក្រុមហ៊ុននាំមុខទីផ្សារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងជាក្រុមហ៊ុនឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប ១៨៥ ពាន់លានដុល្លាអាមេរិក គិតត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាធានារ៉ាប់រងច្រើនជាង ៣០លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង ១៦លាននាក់។

អេ អាយ អេ ខេមបូឌា បានទទួលអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៧។ ដោយមានគម្រោងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងឆ្នាំនេះ អេ អាយ អេ ខេមបូឌា នឹងណែនាំមកនូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងជីវិតដែលថ្មីប្លែក ដើម្បីបំពេញតម្រូវការលើការការពារ និងការសន្សំរយៈពេលវែង របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ អេ អាយ អេ ខេមបូឌា ប្តេជ្ញាចូលរួមលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង។

**អំពីក្រុមហ៊ុន ស្មាត**

ក្រុមហ៊ុន**ស្មាត អាស្យាតា ខូ អិលធីឌី** ជាក្រុមហ៊ុនទូរគមនាគមន៍ចល័តឈានមុនគេក្នុងប្រទេសកម្ពុជា ដែលសព្វថ្ងៃនេះកំពុងបម្រើអតិថិជនជាង ៨ លាននាក់ក្រោមស្លាកសញ្ញា "**ស្មាត**" ។ **ស្មាត អាស្យាតា** គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Axiata Group Berhad ដែលជាសម្ព័ន្ធទូរគមនាគមន៍ធំជាងគេមួយក្នុងទ្វីបអាស៊ី ។

ក្នុងខែមករា ឆ្នាំ២០១៤ **ស្មាត** បានដាក់ដំណើរការបណ្តាញ 4G LTE របស់ខ្លួន ហើយបានក្លាយជាប្រតិបត្តិករដំបូងបង្អស់ ក្នុងប្រទេសកម្ពុជាដែលផ្តល់សេវានេះ។ សេវា 4G LTE របស់ **ស្មាត** ផ្តល់ជូនអ៊ីនធឺណិតទូរស័ព្ទល្បឿនលឿនបំផុតក្នុងប្រទេសកម្ពុជា ហើយបានគ្របដណ្តប់យ៉ាងទូលំទូលាយទូទាំង ២៥រាជធានី-ខេត្ត ។ បន្ថែមពីលើនេះទៀត **ស្មាត** ក៏ផ្តល់ជូនផងដែរនូវ សេវាទូរស័ព្ទ 2G, 2.5G, 3G និង 3.75G ដែលអាចប្រើប្រាស់ជាមួយនឹងពហុប្រព័ន្ធផ្សព្វផ្សាយ និងសេវាអ៊ីនធឺណិតទូរស័ព្ទ ចុងក្រោយបំផុត និងសេវា roaming អន្តរជាតិនៅជាង ១៩០ ប្រទេស ។ នាពេលបច្ចុប្បន្ននេះ បណ្តាញរបស់ **ស្មាត** បានគ្របដណ្តប់ទៅដល់ប្រជាជនកម្ពុជាច្រើនជាង ៩៨% ទូទាំងប្រទេស ។

តាមរយៈភាពជាដៃគូរបស់ខ្លួនជាមួយនឹងក្រុមហ៊ុន Apple ក្រុមហ៊ុន **ស្មាត** បានក្លាយប្រតិបត្តិករតែមួយគត់ដែលមានសិទ្ធិចែកចាយ iPhone និងiPad នៅក្នុងប្រទេសកម្ពុជាបាន ។ លើសពីនេះទៅទៀត **ស្មាត** គឺជាដៃគូផ្តាច់មុខរបស់ Universal Music ក្នុងប្រទេសកម្ពុជា។ Smart ជាក្រុមហ៊ុនដែលលើកស្ទួយការបង្កើតថ្មីបែបឌីជីថល ដោយផ្តល់នូវសេវាបន្ថែម និងសេវាបែបឌីជីថលនានារួមមាន SmartLuy, Smart LifeInsurance, SmartPay, Smart Music និង SmartNas ។

**ស្មាត** ត្រូវបានទទួលស្គាល់ជា ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ចល័តល្អជាងគេនៅកម្ពុជា ប្រចាំឆ្នាំ២០១៦ និងជា ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ ដែលរីកលូតលាស់ឆ្នាំ ២០១៥ នៅទីផ្សារអាស៊ីប៉ា-ស៊ីហ្វិក ពីក្រុមហ៊ុន Frost & Sullivan។ **ស្មាត** ក៏ទទួលបានពានរង្វាន់ជា ក្រុមហ៊ុនទូរគមនាគមន៍ល្អបំផុតក្នុងប្រទេសកម្ពុជា និងជាក្រុមហ៊ុនដែលបានចូលរួមចំណែកការងារសង្គមខ្ពស់បំផុតក្នុងប្រទេសកម្ពុជា បីឆ្នាំជាប់គ្នា គឺឆ្នាំ២០១៥, ២០១៦ និង២០១៧ ដោយ Global Banking & Finance Review ។ បន្ថែមពីនេះ **ស្មាត** រក្សាតំណែងជាក្រុមហ៊ុនឈានមុខគេផ្នែកបណ្តាញអ៊ីនធឺណិតចល័ត ដោយ បានទទួលស្គាល់ថា ជាក្រុមហ៊ុនដែលផ្តល់ល្បឿនអ៊ីនធឺណិតចល័តលឿនជាងគេនៅកម្ពុជាប្រចាំឆ្នាំ២០១៦ ដោយស្ថាប័ន Ookla ។

ក្រុមហ៊ុនមានបុគ្គលិកជាង ១០០០ នាក់ ដែលរួមមានទាំងអ្នកជំនាញក្នុងស្រុក និងអន្តរជាតិ ។ ក្រុមហ៊ុន**ស្មាត** បានប្តេជ្ញាចិត្តជូនដល់អតិថិជន បុគ្គលិក និងប្រជាជនកម្ពុជាក្នុងការធ្វើអោយជីវិតរបស់ពួកគេកាន់តែប្រសើរឡើង ។

"**ស្មាត** ជីវិតរស់រវើក" ។

**ទំនាក់ទំនងសារព័ត៌មាន៖**

ហាក់ បញ្ញារ័ត្ន
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
០១៦ ៣៦៩ ១៥៥
Panharath.Hak@aia.com

មិត្ត ហាក់
អ្នកទទួលបន្ទុកផ្នែកទំនាក់ទំនងសាធារណៈ
ស្មាត អាស្យាតា ខូអិលធីឌី
០១០ ២០២ ២៧១
mith.hak@smart.com.kh